# នៅមុខខ្លោងទ្វាររោងចក្រ

ឈុតទី 6/6



អង្គការ
ពលកម្ម
អន្តរជាតិ

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា


នែ៎! ថ្មម៉ាដុំហ្នឹង វ៉ៃឱ្យស្រួលៗបន្តិចទៅ! កុំមួយថ្ងៃ ទៅអង្គួលតែម៉ាដុំហ្នឹងអញ្ចឹង នោះ!
ហ៊ឺ....មើលទៅពួកឯងបែបចាស់ធ្វើការងារ នេះលែងកើតហើយ.....ខ្ញុំក៏ចង់ជួយដែរ តែមើលចុះ គ្នាពួកឯងពីនាក់កំពុងតែនាំគ្នា ធ្វើការងារតែតែម្នាក់ទៅទៀតក៏!
លោកអើយ...ខ្ញុំត្រូវការការងារនេះខ្លាំងណាស់ ....តែបន្តិចទៅ ខ្ញុំជាវិញហើយ.....ម៉ោពីកំទេចដុំថ្ម អស់ហ្នឹងហើយក្រុមហ៊ុនក៏អត់មានឱ្យម៉ាស៊ីនប្រើ អញ្ចឹងហើយបានជា.....
កុំបន្ទោសក្រុមហ៊ុន......បើគ្មាន ការងារនេះទេ ពួកឯងក៏គ្មានអី ធ្វើដែរ !
រឿងនេះពួកឯងត្រូវតែដោះស្រាយ ខ្លួនឯងទៅ ព្រោះមានក្មេងៗច្រើន ណាស់ កំពុងតំរង់ជួរចាំធ្វើការងារនេះ
កុំពិបាកចិត្តពេកអីពុកវា.....ស្រីមុំ និង បុប្ផាជិតមកដល់ហើយ..... ពួកវានៅរោងចក្រខំធ្វើការណាស់ ។ ពេលវាមកវិញ វាឡូស់ ជាទិញក្រម៉ាឱ្យពួកយើងខ្លះមិនខាន ។
មេការប្រាកដជានិយាយត្រូវ.....ខ្ញុំឥឡូវ នេះចាស់ពេកហើយ សំរាប់ការងារនេះ តើឱ្យខ្ញុំទៅ ធ្វើស្អីវិញទៅ...? .....មើលចុះ តាមពិតទៅពេលនេះ សុផលគួរតែកំពុងរៀននៅសាលា...មិនមែនមកនៅ ជួយធ្វើការយើងនោះទេ......ហើយកូនស្រីយើងនៅ ភ្នំពេញ ឥឡូវម៉េចហើយទេ...?

នៅតាមផ្ទះជួលរបស់កម្មករនារសៀលមួយ........................




ដឹងរឿងអីបុប្ផា...?
អឺ...គឺ ខ្ញុំ...ខ្ញុំខ្លាចគេដឹងថា វាមិនសូវបានញ៉ាំអីគ្រប់គ្រាន់ហ្នឹងម្ល៉ោះ.....មិនអញ្ចឹងអ្ហែ មុំ?
ម៉េចដែរទាំងអស់គ្នាថ្ងៃនេះ អត់មានបញ្ហាអីទេអ្ហែ?
អឺ...បុប្ផា....ស្រីមុំប្អូនស្រីបុប្ផាឯង ឈឺទៀតហើយអ្ហែ បានព្រឹកនេះអត់ឃើញមកធ្វើការ....នាងឈឺទៀតហើយ រឺ ?
ពិតមែនអ្ហែ... វាអត់ទាន់មកធ្វើការទៀត?!
បើតាមប្រធានផ្នែកប្រាប់មកខ្ញុំ ខែនេះស្រីមុំឈប់៥ថ្ងៃហើយ....
តែពេលពួកខ្ញុំចេញមកធ្វើការព្រឹកមិញ វាស្រែកប្រាប់ថា វារៀបចេញមកដែរហើយតើ...


កញ្ញាបុប្ផាឯងទៅជួបនិយាយរឿងនេះជាមួយខ្ញុំនៅការិយាល័យ.... .... អ្នកស្រីប្រធានបានប្រាប់ខ្ញុំឱ្យត្រួតពិនិត្យចំនួនថ្ងៃ ឈប់សំរាកឈឺរបស់ បុគ្គលិក ដោយទុកវាជាកិច្ចការមួយដ៏សំខាន់ក្នុងការបង្កើនផលិតភាពនៅ ក្នុងរោងចក្ររបស់យើង
ខ្ញុំសន្យាថា វាលែងឈប់អញ្ចឹងទៀត ហើយ....ការងារក្នុងរោងចក្រនេះសំខាន់ សំរាប់វាខ្លាំងណាស់ពូ.....
បុប្ផា...ខ្ញុំដឹង ថាមនុស្សជាច្រើនត្រូវការការងារ .....បើនិយាយឱ្យត្រង់ទៅ...ខ្ញុំបារម្ភថា ក្នុងរឿងនេះ ហាក់បីដូចជាមានបញ្ហា....ប្អូនបុប្ផាឯងមើលទៅ ដូចជានៅក្មេងណាស់.....
តែក្រុមហ៊ុនបានមើលដឹងអ៊ីង និង ត្រួតពិនិត្យប័ណ្ណគ្រួសារនាង ដែរតើអ្វី?
ត្រូវហើយ....ខ្ញុំដឹង..... ឯកសាររបស់នាង ក៏ដូចជាត្រឹមត្រូវហើយ ។ យ៉ាងណាសូមឱ្យតែ នាងជា និង អាប់ត្រលប់មកធ្វើការវិញបាន ចុះ ។



មុំ....ឯងឈឺអី ? ក្រោកឡើងមកអូន... ឆាប់ក្រោកឡើង....ឯងកុំឈឺឱ្យសោះណា.... !
ខ្ញុំស្រេកទឹកណាស់បង....ជួយយកទឹកឱ្យខ្ញុំបន្តិចមើ៉ា.......
ស្តាប់បងសិនមុំ....បងគិតថាពួកប្រធានធនធានមនុស្សប្រហែលជាកំពុងតែសង្ស័យលើឯងហើយ....ឯងត្រូវតែជាវិញភ្លាម....យើងគ្មានលុយឱ្យពេទ្យទៀតទេ....
ខ្ញុំដឹងហើយបង....ខ្ញុំកំពុងតែព្យាយាមហើយ តែខ្ញុំអស់កម្លាំងខ្លាំងពេក....ក្នុងខ្លួនរបស់ខ្ញុំដូចជាខ្សោយណាស់បង ។
ក្រោយមក.............
អ៊ូយ....បង.... អ៊ូយ .....ជួយផង..... ឈឺណាស់ ....អ៊ូយ.....!!!
មិនត្រូវកើតឡើងទេ ! ប្អូនស្រីខ្ញុំមុតដៃ !
ស្រីមុំ... ឯណាកញ្ចក់ចាំងការពារម្ជុលម៉ាស៊ីនឯង? ម៉េចក៏មិនឃើញ?...ឱ្យខ្ញុំមើលដៃបន្តិចមើល៍....ហើយរឿងកើតឡើងយ៉ាងម៉េចទៀតកំ?
ឱ្យខ្ញុំសូមទោសផងបង....ខ្ញុំប្រហែលជាងោក.....អូ អត់ទេ.... គឺម៉ោពីខ្ញុំមិនបានប្រយ័ត្ន ហើយក៏.....
បានហើយ....ឯងប្រញាប់ទៅពេទ្យរោងចក្រយើងឥឡូវនេះភ្លាមទៅ.....ម៉ាព្រឹកនេះខ្ញុំឃើញឯងស្លេករហូត ហើយឥឡូវក៏....បានហើយ...បន្ថែមទៀត ទៅការិយាល័យលោកប្រធាន ធនធានមនុស្សជាមួយខ្ញុំ ។


ហើយចុះមានបញ្ហាអីដែរ?
គឺរឿងស្រីមុំ... នាងឈប់ធ្វើការច្រើនថ្ងៃហើយ ហើយថ្ងៃនេះនាងមកនៅពេលដែលកំពុងធ្វើការ និង បណ្តាលឱ្យរបួសខ្លួនឯងទៀត ។
ស្រីមុំឯងកើតអីទៅខ្លួន? ហើយមានបានទៅឱ្យពេទ្យមើលទៅ? ខ្ញុំមិនយល់សោះ ថាស្រីមុំឯងមានរឿងអី...? ហេតុអីបានជាមុំឯងអវត្តមានមិនបានមកធ្វើការច្រើនថ្ងៃម្ល៉េះ? ហើយនៅពេលដែលមកធ្វើការហើយបែរជាផ្ដួលក្នុងពេលកំពុងធ្វើការទៀត ។
អឺ បងម៉ា....ខ្ញុំស្គាល់ស្រីមុំ ហើយគ្រួសារនាងក៏ខ្ញុំស្គាល់ច្បាស់ណាស់ដែរ....រឿងនេះបងទុកឱ្យខ្ញុំដោះស្រាយចុះ....នាងប្រហែលជា ទៅដើរលេងជាមួយសង្សារដល់យប់ជ្រៅពេកហើយមើលទៅ....
រឿងនេះធ្ងន់ធ្ងរណាស់....មិនមែនលេងសើចទេណាកុសល្យ! ពួកយើងកំពុងតែខិតខំធ្វើយ៉ាងណា អភិវឌ្ឍន៍រោងចក្រយើងឱ្យបានល្អឡើង ហើយចំពោះឧបទ្ទវហេតុបែបនេះ យើងត្រូវតែស៊ើបឱ្យដឹងពីមូលហេតុពិតរបស់វាឱ្យបានច្បាស់ទើបបាន!
ស្រីមុំ...កុំឲ្យវិលវល់និយាយប្រាប់បងប្រធានតាមត្រង់ទៅ...យប់មិញឯងទៅដើរលេងដល់យប់ជ្រៅកន្លែងណាខ្លះ....កន្លែងមួយដែលខ្ញុំឃើញឯងនោះ......
ចាំ...ចាំ.....មែនហើយពូ.....ខ្ញុំសូមទោស....យប់មិញខ្ញុំដើរលេងដល់យប់ជ្រៅមែន ហើយក៏...


ចំពោះរឿងនេះខ្ញុំសូមនិយាយបន្តិចចុះលោកបង...ខ្ញុំគិតថា យើងគួរតែត្រួតពិនិត្យមើលដីម៉ង់របស់ស្រីមុំ រឺក៏ សៀវភៅគ្រួសាររបស់នាងឡើងវិញទៅ.....នាងមើលទៅដូចជានៅក្មេងណាស់ ដារ៉ា និងខ្ញុំបារម្ភខ្លាចតែនាងឈឺដោយសារការខំធ្វើការពេក ហើយញ៉ាំមិនបានគ្រប់គ្រាន់ទៀត....
ខ្ញុំដឹង...ហើយខ្ញុំក៏កំពុងតែគិតដូចដែលលោកបងបាននិយាយប៉ុន្មានដែរ....ខ្ញុំក៏ធ្លាប់បានពិនិត្យមើលឯកសាររបស់នាងរួចហើយដែរ គឺដូចជាអត់មានបញ្ហាអីទេ....ប៉ុន្តែ ប្រហែលជាកាលនោះ ខ្ញុំមើលមិនបានល្អិតល្អន់ រឺក៏រំលងចំណុចណាមួយ ហើយមើលទៅ....
ស្រីមុំ....តើប្អូនមានដឹងទេថា ក្នុងការដែលប្អូនអាចធ្វើការក្នុងឧស្សាហកម្មកាត់ដេរនេះបាន ប្អូនត្រូវមានអាយុយ៉ាងតិច១៥ឆ្នាំ និង ក្នុងការដែលប្អូនអាចធ្វើការថែមម៉ោងនៅពេលយប់បាន ប្អូនត្រូវមានអាយុយ៉ាងតិច១៨ឆ្នាំ?


ស្រីមុំ.....ឆ្នាំកំណើតពិតប្រាកដប្អូនកើតឆ្នាំណាដែរ?......មានដឹងទេ.....ប្អូនឯងកើតឆ្នាំអី?
ខ្ញុំ.....អឺ...ដូចជាកើតឆ្នាំ៨០ជាង.....អឺ...ដូចជា៨៨ មិនដឹង ៨៥ មិនដឹងទេ...
ប្អូននិយាយអញ្ចឹងមានន័យថាប្អូនក៏មិនច្បាស់ខ្លួនឯងដែរ មែនទេ? ស្រីមុំ....ខ្ញុំចង់ឱ្យប្អូនឆ្លើយឱ្យស្មោះត្រង់......តើប្អូនធ្លាប់បានកែប្រែអ្វីនៅក្នុងប័ណ្ណគ្រួសារឬមិនក៏យកប័ណ្ណគ្រួសារទៅឱ្យគេធ្វើការកែរបន្លំអីទេ?
សូមលោកស្រីអនុញ្ញាតិអោយនាងសំរាកបន្តិច នាងដូចជាភ័យនឹងសំនួរលោកស្រីហើយ ?
សំរាប់រឿងនេះ នាងខ្ញុំចង់ស្នើរឱ្យរោងចក្រអនុញ្ញាតិច្បាប់ឱ្យស្រីមុំដោយមិនមានកាត់ប្រាក់ខែអ្វីទាំងអស់ ដើម្បីឱ្យនាងត្រលប់ទៅផ្ទះនៅឯស្រុក យកឯកសារដែលសមស្របពីក្រុមគ្រួសារ និងអាជ្ញាធរដែនដីមក ខ្ញុំមានអារម្មណ៍ថា ថ្ងៃខែឆ្នាំកំណើតនៅលើឯកសារទាំងអស់នេះត្រូវបានគេលួចកែរ.....យើងមើលតែកន្លែងនេះទៅដឹងហើយ.....ប្រឡាក់ញើសប្រឡាក់ ហាក់បីដូចជាមាននរណាម្នាក់បានព្យាយាមកោស លុបលេខពីច្បាប់ដើមអញ្ចឹង....
19.05 1965
20.01 1985
21.02 1988
10.07 1994
ត្រឹក...!
ឈ្មោះលោកកុសល្ប ក៏ដូចជាហត្ថលេខារបស់លោកប្រធានគ្រប់គ្រងធនធានមនុស្សដែលតែងមានជាប់នៅលើវិញ្ញាបនបត្រខាងក្រោមជាមួយរបស់ស្រីមុំ ហើយឈ្មោះលោកគឺជាអ្នកដែលបាននាំស្រីមុំឱ្យចូលធ្វើការក្នុងរោងចក្រនេះទៀត ។
លោកនិយាយអ្វីហ្នឹង? ... ឱ្យខ្ញុំមើលមើល៍...ត្រូវហើយ....តើវាមានបញ្ហាអីទៅ? មនុស្សភាគច្រើនតែណែនាំមិត្តភក្តិ បងប្អូនគេឱ្យចូលធ្វើការតែអញ្ចឹង ។
លោកថាអញ្ចឹងក៏បាន ប៉ុន្តែនៅក្នុងនេះមានចំនុចមិនសមស្របច្រើនណាស់.....មុខមាត់ស្រីមុំស្តែងឱ្យឃើញច្បាស់ណាស់ថានាងមិនទាន់គ្រប់អាយុធ្វើការនៅឡើយនាងមានរូបរាងស្គមស្គាំង និងឧស្សាហ៍ឈឺទៀត....។


ពីរ បីថ្ងៃកន្លងផុតទៅ.........................................
បងស៊ីណា ខ្ញុំសប្បាយចិត្តណាស់ដែលបាន បងមកជាមួយ.....ខ្ញុំខ្លាចរឿងដែលពូ-មីង មកពីអង្គការ ILO អស់ហ្នឹងកំពុងស្រាវជ្រាវដល់ហើយ...ហើយ ខ្ញុំមិនដឹងថាត្រូវទៅប្រាប់អាជ្ញាធរដែនដី យ៉ាងម៉េចទេ....
ស្រីមុំ...ឯងគ្មានអីត្រូវបារម្ភទេ.... ស្រីមុំ...ឯងអត់មានកំពុងតែលាក់បាំងរឿងអីទេ មែនទេ?
ស៊ីណា....អឺ...នែ.... តែឯងកុំខឹងនឹងពួកខ្ញុំឱ្យសោះណា....ពួកយើងគ្មានបំណងចង់បង្កបញ្ហាដល់នរណាម្នាក់នោះទេ តែ.....
ឯងនិយាយអីហ្នឹង...? ខ្ញុំមិនយល់ទេទៀត.......បុប្ផា...ប្អូនឯង ស្រីមុំ មានកុហកពីអាយុពិតប្រាកដនៅក្នុងជីវិតការងារនាងដែរអត់....?
អាមុំពិតជាកូនក្មេងអាយុមែន....ឱ្យខ្ញុំសូមទោសបងស៊ីណា....បើនិយាយទៅឯងដូចជាបងប្អូនខ្ញុំអញ្ចឹង....ខ្ញុំខ្មាសខ្លួនឯងណាស់ ព្រោះ... សូម្បីតែឯងក៏ពួកខ្ញុំកុហកដែរ.....
....ស្រីមុំ....ពួកយើងគួរតែប្រាប់រឿងរ៉ាវទាំងអស់ទៅស៊ីណាតែម្ដងទៅ....


រឿងរ៉ាវទាំងអស់ចាប់ផ្ដើមឡើងបន្ទាប់ពីពេលដែលបងស្រីខ្ញុំបានចាកចេញទៅធ្វើការនៅភ្នំពេញ....ពុកធ្លាក់ខ្លួនឈឺជាងមួយអាទិត្យ ហើយគេក៏បញ្ឈប់ការងារគាត់.....ខ្ញុំសុំឈប់រៀន ហើយចង់ទៅរកការងាររោងចក្រធ្វើដូចបងស្រី......
រោងចក្រជាច្រើនមិនព្រមទទួលខ្ញុំ...គេថាខ្ញុំនៅក្មេងពេក ។ ចុងក្រោយ ខ្ញុំក៏សុំលេខទូរសព្ទការបងស្រីខ្ញុំ...ពីបុរសគាត់ខ្វាយខ្វល់ណាស់ គាត់សើរតែមិនបានយកខ្ញុំមករោងចក្រដែលនេះទេ...គាត់ខ្លាចគាត់បាត់ការងារបើគេដឹងថាគាត់នាំខ្ញុំនៅក្មេងពេក មិនទាន់គ្រប់អាយុដែលច្បាប់អនុញ្ញាតិឱ្យធ្វើការ...តែទីបំផុតគាត់ក៏ព្រមនាំខ្ញុំទៅ....
.....ខ្ញុំបានជួបបងស្រីម្នាក់នៅមុខរបងរោងចក្រ ដែលអាចជួយអោយខ្ញុំបានធ្វើការបាន ដោយសារគាត់មានស្គាល់គេនៅខាងក្នុងរោងចក្រ ។ យើងត្រូវអោយលុយគាត់ ដើម្បីអោយកែឯកសារ....
ស្អែកឡើង ខ្ញុំក៏ទៅ ហើយក៏បានជួបបងស្រីម្នាក់នោះមែន.....ពេលនោះគាត់ទូរស័ព្ទទៅគេម្នាក់ ហើយបន្តិចក្រោយមកពូកុសល្យក៏ចេញមក......ខ្ញុំយកលុយបន្តិចបន្តួចដែលខំសន្សំជូនទៅគាត់....ប៉ុន្តែទោះជាអញ្ចឹងក៏ដោយ ខ្ញុំក៏បានការងារធ្វើពិតមែន.....
តែ ពីរខែកន្លងផុតទៅ នៅក្នុងការិយាល័យលោកស្រីប្រធានរោងចក្រ...........................
ឥឡូវនេះយើងបានឃើញច្បាស់ណាស់ថាវិធីរកលុយខុសច្បាប់របស់កុសល្យនេះត្រូវបានធ្វើឡើង យ៉ាងយូរមកហើយ....ខាងខ្ញុំបានសើរើរឹងឯកសារចាស់ៗពីប៉ុន្មានឆ្នាំមុនមកមើល ហើយឃើញឈ្មោះកុសល្យជាប់នៅសឹងគ្រប់កន្លែង...!
រឿងបែបនេះខាងខ្ញុំធ្លាប់បានឃើញដែលៗ ជាច្រើនលើកច្រើនសារួចមកហើយ
ប៉ុន្តែរឿងនេះវាខុសពីច្បាប់ទាំងស្រុងហើយ ច្បាប់ការងារគឺបានសរសេរច្បាស់ណាស់អំពីបញ្ហានេះ....គ្មាននរណាមានសិទ្ធិទាមទារលុយពីគាត់ ដើម្បីទុកអោយនៅក្នុងដំណើរការជ្រើសរើសបុគ្គលិកជាដាច់ខាតទោះបីជាគេនៅក្នុងឋានៈណាក៏ដោយ!


ដូចខ្ញុំបានជំរាបអ្នកស្រីពីខាងដើមមកហើយ ថា រឿងនេះវាបានកើតឡើងញឹកញាប់ណាស់ទៅហើយតាមរយៈក្មេងៗទាំងអស់នោះកំពុងតែស្រេកឃ្លានចង់បានការងារធ្វើ.... ទោះគេមានលុយតិចតួចក៏ដោយ សំណាងល្អហើយ ដែលស្រីមុំ ក្លាហាន.....
ខ្ញុំក៏សូមអរគុណអ្នកស្រីដែលបានអនុញ្ញាតិឱ្យកូនស្រីមកចូលរួមជួយនៅក្នុងការងារនេះ.....មុខមាត់កូនអ្នកស្រីពិតជានៅក្មេងមែន...មើលទៅអាយុប្រហែល១៥ទើបស្រីមុំដែរប៉ុន្តែថ្មីៗគឺកែអញ្ចឹងមែន យើងទាំងអស់គ្នាសុទ្ធតែដឹងច្បាស់ ថាខាងមានអាយុអាចចូលធ្វើការ ដោយស្របច្បាប់បាន ។
ចាំ មិនអីទេលោក....ខ្ញុំសប្បាយចិត្តនឹងជួយអោយអស់លទ្ធភាពដែលខ្ញុំអាចធ្វើទៅបាន ហើយកូនស្រីខ្ញុំក៏អញ្ចឹងដែរ.... នាងមានអាយុ ១៩ឆ្នាំ ហើយសំរាប់រឿងនេះគឺគ្មានអ្វីខុសទាស់ទាំងអស់.....ឥឡូវយើងនាំគ្នាចាំមើលចុះ ថាតើគេនាំគ្នាដាក់កូនខ្ញុំអាយុប៉ុន្មាននៅក្នុងដីម៉ង...?
STAR


តែប៉ុណ្ណេះបានបាត់ទៅហើយ ឃើញទេ...អត់ចាស់ហួស! អូនកើតនៅឆ្នាំ ១៩៨៨ អូនឯងឥឡូវអាយុគ្រប់បីគ្រប់ ដប់ (១៨) ហើយ..... ហើយក៏គ្មានអ្នកណាដឹងពីការកែនេះ ដែរ.....។
ស្អាតមែនតើស៎ ពូ......ការងារហ្នឹងពូឯង ប្រហែលធ្វើច្រើនដងហើយមើលទៅ បាន ជំនាញម្លេះ.....
បាះ....មានអី ស្រួលសឹងអីហ្នឹង.... អារឿងអញ្ចឹង១ ពូធ្វើរាប់ឆ្នាំមក ហើយ....
ខ្ញុំអរគុណច្រើនហើយពូ....ចុះខ្ញុំចូល ធ្វើការនៅណាទៅ? ហើយប្រាក់ខែ ខ្ញុំបានប៉ុន្មានដែរ?
....មិនបាច់ប្រញាប់ពេកទេ..... ទុកពេល ឱ្យពូម៉ា ថ្ងៃពីរ ដើម្បីរៀបចំប្រវត្តិរូបថ្មីអូនឯង និង យក ឯកសារទៅឆ្លងរដ្ឋបាលផង......
ល្បែងឯងមួយនេះត្រូវចប់ហើយ.... ក្មេងម្នាក់នេះគឺជាកូនស្រីខ្ញុំ....គោលតែ ឯងនេះបោកប្រាស់ធ្វើបាបកម្មករយក ប្រាក់ខែគេអញ្ចឹងទៅកើត....
ខ្ញុំមិនទាំងស្គាល់ក្មេងម្នាក់នេះផង....... នាងមកជួបខ្ញុំ ហើយសុំឱ្យខ្ញុំជួយយក ឌីម៉ង់នាងបញ្ជូនទៅផ្នែករដ្ឋបាលឱ្យ.... ចុះនេះអ្នកស្រីចង់ធ្វើអីខ្ញុំហ្នឹង?


តើលោកមានបានទទួលលុយពីក្មេងស្រីម្នាក់នេះដើម្បីធានាឱ្យនាងបានការងារធ្វើនៅក្នុងរោងចក្រដែរទេ?
អត់...អត់មានទេលោក...ខ្ញុំស្បថឱ្យក៏បានដែរ....ខ្ញុំប្រាប់លោកហើយតើ ថានាង អត់មានបានឱ្យលុយអីមកខ្ញុំទេ...!
អញ្ចឹងចុះចំពោះលុយក្រដាស ១០ដុល្លា ៨សន្លឹក នៅក្នុងហោប៉ៅខោលោកនេះ លោកចង់បកស្រាយយ៉ាងម៉េចវិញ?
លោកយកលុយទាំងអស់នោះចេញមកពិនិត្យមើល សុទ្ធតែមានសញ្ញាពណ៌ខៀវតូចមួយនៅជ្រុងខាងលើផ្នែកខាងស្តាំ.... ព្រោះខ្ញុំជាអ្នកដាក់ចំណាំ ហើយលុយអស់នោះក៏ខ្ញុំជាអ្នកឱ្យទៅក្មេងស្រីនេះដើម្បីយកមកបង់ឱ្យលោកដែរ!
បក្សពួកកុសល្បួងដែលនៅទីនេះ បានសារភាពអស់ហើយថាគេបានរួមគំនិតនៅក្នុងអំពើនេះអស់ជាច្រើនឆ្នាំ ដោយប្រើប្រាស់តំណែងរបស់ខ្លួនជាប្រធានផ្នែក....




ពីរ បីសប្តាហ៍ក្រោយមក នៅឯសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ................................




និយាយទៅនៅឯរោងចក្រ អ្នកណាគេក៏ចូលចិត្តស្រីមុំដែរ.....ដោយសាររោងចក្រមានកំហុសក្នុងការពិនិត្យឯកសាររបស់ស្រីមុំ មិនបានត្រឹមត្រូវ ដូចនេះ ពួកគេយល់ព្រមជួលនាងវិញ ពេលនាងអាយុ១៨ ឆ្នាំ ។
រោងចក្រក៏បានផ្តល់ប្រាក់ខែអោយនាង និងបង់ថ្លៃបណ្តុះបណ្តាលទៅទីនេះ ។ ការបណ្តុះបណ្តាលនៅក្នុងមជ្ឈមណ្ឌលនេះ និងជួយនាង នៅពេលនាងត្រលប់ទៅធ្វើការវិញ ។
កន្លែងនេះពិតជាល្អខ្លាំងណាស់អ្នកគ្រូ... ហើយខ្ញុំសូមអរគុណអ្នកគ្រូមែនទែន ដែលអ្នកគ្រូបានជួយបណ្តុះបណ្តាលក្មេងៗជាច្រើន....
ខ្ញុំក៏សូមអរគុណប្អូនជាងដែរ....ប៉ុន្តែបើនិយាយទៅ ខ្ញុំគ្រាន់តែជាចំណែកតូចមួយតែប៉ុណ្ណោះទេ ពីព្រោះមានមនុស្សជាច្រើនទៀតដែលបានចូលរួមចំណែកជួយ.....
នៅពេលដែលនាងកំពុងរៀននៅទីនេះ ប្រាក់ខែរបស់ស្រីមុំត្រូវបានបើកឱ្យតាមរយៈកិច្ចព្រមព្រៀងមួយ ជាមួយអង្គការ ILO និងអង្គការ GMAC. ក្រសួងការងារក៏បានជួយជាគ្រឿងសម្ភារៈបរិក្ខាជាច្រើនដែរ ។
យ៉ាងហោចណាស់នៅកន្លែងនេះ ពួកគេអាចបានរៀនសូត្រ និង មិនចាំបាច់ដើរត្រាច់ចរ រកការងារធ្វើនៅតាមផ្លូវហើយក្លាយខ្លួនទៅជាជនរងគ្រោះរបស់ពួកមនុស្សបោកប្រាស់ទាំងអស់នោះដែរ...វាជាការប្រសើរខ្លាំងណាស់ដែលពួកគេអាចទទួលបាននូវការគាំទ្រទាំងអស់នេះ និង ថែមទាំង មានកន្លែងស្នាក់នៅ ក្នុងពេលដែលពួកគេកំពុងរៀនសូត្រ ។
រឿងនេះយើងមិនទាន់អាចថាល្អឥតខ្ចោះនៅឡើយទេ ប៉ុន្តែវាជាការវិវត្តន៍មួយគួរឱ្យកត់សំគាល់....នៅពេលដែលស្រីមុំមកទីនេះដំបូង នាងមានសុខភាពមិនសូវល្អទាល់តែសោះ.....


ជំរាបសួរ ពូ មីង
បាទ -ចាស
ប្អូនស្រីតូច.....ថ្ងៃណាមួយយើងប្រាកដជានឹងបានជួប គ្នានៅភ្នំពេញ ម្តងទៀតមិនខាន....ជួយមើលថែពុកម៉ែ និងប្អូនផងណា ហើយត្រូវចាំថា ពួកបងនឹងនៅចាំ ជួយជ្រោមជ្រែងឯងជានិច្ច ទុកចិត្តបងចុះ!
ថែរក្សាខ្លួនប្អូនស្រី ជួបគ្នានៅរោងចក្រក្នុងពេល ឆាប់ៗ ។

**សេចក្តីថ្លែងអំណរគុណ**

សៀវភៅនេះត្រូវបានរៀបរៀង និង ផលិតដោយបុគ្គលិករបស់អង្គការ ILO ***កម្មវិធីរោងចក្រកាត់ដេរប្រសើរនៅកម្ពុជា*** លោក ខននី ប៉ុយ, លោក ជុំ ផល្លី, លោក នៅ តារា និង លោក វុធ លីណូ ។ ម្ចាស់ជំនួយសូមថ្លែងអំណរគុណជាពិសេសចំពោះ លោក និក រ៉ូជី (Navigator Communications) អ៊ុន ផល្លីកា, លោក ញ៉ែម សុផន្ទ, លោក ឈិន ស៊ីណារ៉ាក់, កញ្ញា ឱក សុមាលីម៉ា, លោក នៅ គីសាន់, វ៉ារីដា និង លោក ផល សុភី (ដែលជាតួសំដែងកាយវិការត្រូវបានថតរូបយកដូចបេះបិទ) សំរាប់ការបរិច្ចាគរបស់ពួកគេដើម្បីផលិតជាសៀវភៅនេះឡើង ។

**វិចិត្រគំនូរដោយ**

លោក ចូសេ អែនស៊ីណា

**Illustrations & Layout by**
**Jose Encinas jose@tonle.net**

**ឧបត្ថម្ភថវិការដោយ**

សៀវភៅនេះត្រូវបានផលិតឡើងក្រោមការឧបត្ថម្ភថវិកាតាមរយៈកិច្ចព្រមព្រៀងប្រែប្រួលរួមគ្នារវាង មូលនិធិ GAP និង អង្គការ ILO ***កម្មវិធីរោងចក្រកាត់ដេរប្រសើរនៅកម្ពុជា***។ ***កម្មវិធីរោងចក្រកាត់ដេរប្រសើរនៅកម្ពុជា***ត្រូវបានឧបត្ថម្ភជាថវិការដោយ:

អ្នកផ្តល់ជំនួយ

- ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ទីភ្នាក់ងារជំនួយ និងអភិវឌ្ឍន៍អន្តរជាតិញូហ្សេឡែន
- រាជរដ្ឋាភិបាលកម្ពុជា
- ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ

ក្រុមហ៊ុនដែលបានឧបត្ថម្ភជាថវិកាដល់គំរោង និងបានអនុញ្ញាតិអោយប្រើឈ្មោះរបស់ពួកគេ:

- Sears Holdings Corporation
- Gap Inc.
- Levi Strauss & Co.
- H & M Hennes & Mauritz
- Reebok
- Wal-Mart Stores, Inc.
- Phillips - Van Heusen Corporation


សំរាប់ពត៌មានបន្ថែមសូមទំនាក់ទំនង:

***រោងចក្រកាត់ដេរប្រសើរនៅកម្ពុជា***

**អង្គការពលកម្មអន្តរជាតិ**

លេខ៥ ផ្លូវលេខ៣២២ បឹងកេងកង១

ភ្នំពេញ កម្ពុជា

ប្រអប់សំបុត្រលេខ ២៦៥២

ទូរស័ព្ទ : (+៨៥៥) ២៣ ២១២ ៨៤៧
(+៨៥៥) ២៣ ២២០ ៣៦២

ទូរសារ : (+៨៥៥) ២៣ ២១២ ៩០៣

អ៊ីមែល : betterfactories@ilo.org

វ៉ិបសាយ : www.betterfactories.org/ilo

# សារសំខាន់ៗដកស្រង់ពីឈុតនេះ

- អាយុអប្បបរមាដែលអនុញ្ញាតិអោយធ្វើការបាន គឺ ១៥ឆ្នាំ
- កម្មករនិយោជិតអាយុតិចជាង ១៨ឆ្នាំ មិនអនុញ្ញាតិអោយធ្វើការយប់ទេ
- និយោជក មិនត្រូវជួលកម្មករដែលអាយុតិចជាង ១៨ឆ្នាំ ធ្វើការងារគ្រោះថ្នាក់
- និយោជក ត្រូវរក្សាភស្តុតាងពីអាយុរបស់កម្មករនិយោជិតរបស់ខ្លួនទាំងអស់